**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ៖ ២៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## រូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន។

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសរសេរអក្សរកាត់ថា ស.ប.ស.ហ. ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សរសេរអក្សរកាត់ថា ប.ស.ហ.ក. និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សរសេរអក្សរកាត់ថា ស.ហ.ក.។

**មាត្រា២ .-**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានអត្ថន័យ និងទម្រង់ ដូចតទៅ៖

១- អក្សរ «៖» តំណាងឱ្យហិរញ្ញវត្ថុ ពណ៌ទឹកមាសតំណាងឱ្យភាពសម្បូររុងរឿង

២- រូបនាគពីរព័ទ្ធជុំវិញអក្សរ «៖» មានអត្ថន័យដូចតទៅ៖

- ក- នាគតំណាងឱ្យការថែរក្សា និងការការពារប្រព័ន្ធហិរញ្ញវត្ថុ
- ខ- នាគព័ទ្ធតំណាងឱ្យវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មបានតាមគ្រប់រូបភាព
- គ- ពណ៌ខៀវចាស់តំណាងឱ្យស្វយ័តភាព សាមគ្គីភាព ភាតរភាព សុចរិតភាព ការសម្ងាត់វិជ្ជាជីវៈ និងជំនឿទុកចិត្ត។

៣- ផ្នែកខាងលើនាគមានអក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**" និងផ្នែកខាងក្រោមមានអក្សរជាភាសាអង់គ្លេស "Anti-Money Laundering and Combating the Financing of Terrorism Authority"។

ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាចប្រើប្រាស់រូបសញ្ញានេះទាំងមូល ឬដោយផ្នែកបាន។

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មាននៅក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ប្រើប្រាស់សម្រាប់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងករណីផ្សេងៗទៀត។

**មាត្រា៤ .-**

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មមានត្រាមូលពីរគឺ ត្រាប្រើប្រាស់សម្រាប់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងត្រាប្រើប្រាស់សម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានវ័ណ្ឌពីរជាន់រំលេចរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៜ» នៅចំកណ្ដាល។ នៅខាងក្រោមរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៜ» មានឆ្លាក់អក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**"។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវ័ណ្ឌ និងផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**" ស្របតាមវ័ណ្ឌ។ ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានវ័ណ្ឌពីរជាន់រំលេចរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៜ» នៅចំកណ្ដាល។ នៅខាងក្រោមរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៜ» មានឆ្លាក់អក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**"។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវ័ណ្ឌ និងផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**" ស្របតាមវ័ណ្ឌ។ ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

បានយកសេចក្តីគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ស.ហ.**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១៖ រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

នៃអនុក្រឹត្យលេខ.២៧៨.អនក្រ.បក.ចុះថ្ងៃទី.៣០.ខែ....ធ្នូ......ឆ្នាំ.២០២១

ឧបសម្ព័ន្ធ២៖ ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២១



**ឧបសម្ព័ន្ធ៣៖ ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**នៃអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២១**

ព្រះរាជាណាចក្រកម្ពុជា

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា